ឆ្នាំនៃធម៌មេត្តាករុណា
2014-2016

# ជីវិត

Life

YEAR OF CHARITY

លេខៈ២១

ព្រឹត្តិបត្រព័ត៌មានពីព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ថ្ងៃទី ០១-៣១ ខែមីនា ឆ្នាំ២០១៤

## ដំណើរទស្សនកិច្ចជាផ្លូវការនៅក្នុងមណ្ឌលសកម្មភាពភ្នំពេញខាងជើង របស់ លោកអភិបាលអូលីវីយេ







## តើនរណាជាបងប្អូនខ្ញុំ?

## គោរពជូនបងប្អូនទាំងអស់ជាទីស្រឡាញ់ក្នុងអង្គព្រះគ្រីស្ត

៣- សូមឲ្យព្រះសហគមន៍ប្ដេជ្ញាចិត្តបម្រើសង្គម

" យើងបានហៅអ្នកមក ស្របតាមសេចក្ដីសុចរិតរបស់យើង ។ អ្នកនឹងប្រោសឲ្យមនុស្សខ្វាក់បានភ្លឺ និងនាំជនជាប់ជាឈ្លើយសឹកចេញពីទីឃុំឃាំង" (អស ៤២,៦-៧)

តាំងពីប៉ុន្មានខែកន្លងមកសង្គមថ្មីមួយកំពុងកើតឡើងនៅមុខយើង ។យើងឃើញការផ្លាស់ប្ដូរប្រែប្រួលខ្លះលេចឡើងយ៉ាងព្រាលៗ យ៉ាងលឿន ឬយ៉ាងយឺតៗក៏យើងមិនដឹងដែរ ។យើងមិនទាន់ដឹងថាតើការផ្លាស់ប្ដូរទាំងនោះនឹងទៅជាយ៉ាងណាទេ ? ព្រះសហគមន៍យើងតូច សម្លេងយើងក៏មិនសូវឮខ្លាំងដែរ។ រដ្ឋធម្មនុញ្ញគោរពសិទ្ធិសេរីភាពសាសនា។ តែក្នុងនាមយើងជាអ្នកផ្ញើជីវិតលើព្រះគ្រីស្តយើងត្រូវប្ដេជ្ញាចិត្តបែរទៅរកអ្នកតូចតាច ដែលសង្គមយើងសង្កត់សង្កិន ត្រូវគេសម្លាប់ដោយមិនត្រាប្រណីទាំងប្រើគ្រឿងឈូសដីមករើរុះផ្ទះគេ និងដេញគេចេញពីលំនៅស្ថានរបស់គេ។ ព្រះជាម្ចាស់ស្ថិតនៅខាងស្ត្រីមេម៉ាយកូនកំព្រា និងជនបរទេស។ យើងម្នាក់ៗក្នុងឋានៈជាអ្នកទទួលអគ្គសញ្ញាជ្រមុជទឹក ត្រូវមានសេចក្ដីក្លាហានហ៊ានជំទាស់តទល់នឹងអយុត្តិធម៌គ្រប់យ៉ាង តទល់នឹងអំពើពុករលួយ ដែលជាប្រយោជន៍តែដល់អ្នកមានកម្លាំងប៉ុណ្ណោះ ដែលធ្វើបាបអ្នកទន់ខ្សោយទៀតផង។ ខ្ញុំសូមឲ្យយើងម្នាក់ៗប្រែចិត្តគំនិតយ៉ាងពិតប្រាកដ។ សង្គមថ្មីប្រកបដោយយុត្តិធម៌ សមភាពនឹងកើតមានឡើងបាន លុះត្រាតែយើងម្នាក់ៗយកចិត្តទុកដាក់នឹងប្រយោជន៍រួម។ យើងជាគ្រីស្តបរិស័ទត្រូវតែទទួលខុសត្រូវរឿងនេះជាដាច់ខាត ។យើងមានមធ្យោបាយតិចដែលអាចប្រើបាន តែយើងម្នាក់ៗមានចិត្តថ្មី យើងអាចធ្វើការផ្លាស់ប្ដូរនេះបាន។ ក្នុងបីឆ្នាំខាងមុខនេះ យើងនឹងអធិដ្ឋានហើយរិះគិតអំពីសេចក្ដីស្រឡាញ់។ ក្នុងបីឆ្នាំខាងមុខនេះ យើងក៏ត្រូវបំពេញកិច្ចការដើម្បីឲ្យជំនឿយើងបង្កើតផលដោយសេចក្ដីស្រឡាញ់ ក្នុងគ្រប់វិស័យនៃសង្គមយើង និងនៅគ្រប់កម្រិត ដែលយើងម្នាក់ៗរស់នៅផ្ទាល់ខ្លួនឬតាមគ្រឹះស្ថានរបស់យើង។ ម្នាក់ៗមានយោបល់របស់ខ្លួនខាងនយោបាយដោយសេរី តែយើងត្រូវធ្វើជម្រើសនិងសម្រេចធ្វើកិច្ចការទាំងអស់តាមពន្លឺរបស់ដំណឹងល្អ។ ព្រះយេស៊ូបានតយុទ្ធរហូត ដើម្បីទាមទារឲ្យជីវិតមានជ័យជម្នះ។ ក្នុងនាមនៃសេចក្ដីស្រឡាញ់និងព្រះហឫទ័យមេត្តាករុណារបស់ព្រះបិតា ចំពោះមនុស្សគ្រប់ៗរូប ហើយក្នុងនាមភាតរភាព ដែលយើងចង់កសាងក្នុងពិភពលោកទាំងមូលនោះ ខ្ញុំសូមឲ្យព្រះសហគមន៍ធ្វើជម្រើសទៅរកជីវិត និងសេចក្ដីសុខសាន្ត ដ្បិតយើងមានព្រះបិតាតែមួយព្រះអង្គគត់។

សូមឲ្យប្រទេសកម្ពុជាយើងបានប្រកបដោយសេចក្ដីសុខសាន្ត
សូមឲ្យមនុស្សលោកបានប្រកបដោយសេចក្ដីសុខសាន្ត
សូមព្រះជាម្ចាស់ប្រទានពរ និងថែរក្សាបងប្អូនជានិច្ចនិរន្តរផង។

**អូលីវីយេ ឆ្មឹតអីស្លែរ**
**អភិបាលភូមិភាគភ្នំពេញ**

## Dear all of you in christ!

3- Let our Church be committed

*I , the Lord , have called you in righteousness . You will open the eyes of theblind, you shall bring forth the captives from prison. (Isaiah 42.6-7 )*

In just the last few months a new society is being born before our eyes. Big changes are taking place rapidly. What form will they take? Our church is small. Our voice is muted.

The constitution respects religious freedom, and because of our faith, we need more than ever to turn resolutely towards the little people of our society who have been pushed out so easily with bulldozers. God is on the side of the widow, the orphan, and the strangers. As baptized Christians, we must take responsibility and courageously denounce all situations of injustice and the corruption that always favors the rich to the detriment of the poor. I call for a true conversion of heart ineach of us. A new society where justice and equality are respected may emerge if everyone takes responsibility for the common good . Our responsibility as Christians is to be engaged. In small ways but with a new heart we can be actors for change. Three years of prayers and reflection on charity must also be a time to act with charity in all sectors of our society and at all levels, whetheras individuals or as institutions. We all haveour own personal political convictions, but our choices and decisions must be made in the light of the gospel. Jesus fought for a fuller life for all. God offers love and mercy to every man and woman, and we must create a brotherhood around the world because we have a single father. I call more than ever for our Church to make choices for life and peace .

PEACE IN CAMBODIA .

PEACE ON EARTH .

God bless you and keep you in his Tender Mercy

+Olivier Schmitthaeusler
Apostolic Vicaraite Phnom Penh

# គ្រីស្តបរិស័ទជនជាតិកូរ៉េបើកផ្សារសប្បុរសធម៌

កាលពីថ្ងៃទី២៣កុម្ភៈ កន្លងទៅនេះក្រុមគ្រីស្តបរិស័ទជនជាតិកូរ៉េបានរៀបចំបើកលក់ផលិតផលកូរ៉េដើម្បីជួយឧបត្ថម្ភដល់ជនក្រីក្រនៅកម្ពុជា នៅព្រះវិហារសន្តយ៉ូសែបផ្សារតូច នារាជធានីភ្នំពេញ។

លោកបូជាចារ្យ ហ្វ្រាន់ស៊ីស្កូ អូ អ៊ីនដុន ជាអ្នកទទួលខុសត្រូវសមាគមគ្រីស្តបរិស័ទកូរ៉េមានប្រសាសន៍ថា៖ សកម្មភាពនេះរៀបចំឡើងដោយគ្រីស្តបរិស័ទជនជាតិកូរ៉េដែលតែងមកថ្វាយអភិបូជាជារៀងរាល់សប្តាហ៍នៅក្នុងព្រះសហគមន៍ផ្សារតូចនេះ។ ការបង្កើតកម្មវិធីនេះគឺដើម្បីរកប្រាក់ចំណូលឲ្យព្រះសហគមន៍ ជួយដល់អ្នកក្រីក្របូប្រើប្រាស់តាមតម្រូវការផ្សេងៗរបស់ព្រះសហគមន៍។



រូបថត: ស្រីម៉ាច

លោកបូជាចារ្យរូបនេះបានបន្តថា៖ ចំពោះការចំណាយទាំងអស់ គឺបានមកពីការរៃអង្គាសពីគ្រីស្តបរិស័ទកូរ៉េផ្ទាល់សម្រាប់ធ្វើជាដើមទុនក្នុងការរកកំរៃនេះ។

នេះជាលើកទី១ហើយ ដែលក្រុមគ្រីស្តបរិស័ទកូរ៉េបានរៀបចំកម្មវិធីនេះឡើង។ ទំនិញនិងផលិតដែលបានដាក់លក់នោះរួមមានសំលៀកបំពាក់ ការ៉េម មីកញ្ចប់ គីមឈី គ្រឿងសម្អាង ម្ហូបចំអិនបែបកូរ៉េ និងគ្រឿងប្រើប្រាស់ផ្សេងៗដែលសុទ្ធសឹងជាផលិតផលនិងអាហារកូរ៉េទាំងអស់។

កញ្ញាសេន ណារី ដែលបានចូលរួមទិញផលិតផលក្នុងកម្មវិធីនោះនិយាយថា៖ នាងពេញចិត្តចូលរួមក្នុងកម្មវិធីនេះព្រោះនាងបានឃើញរបស់របរប្រើប្រាស់និងអ្វីៗផ្សេងៗទៀតដែលនាងមិនធ្លាប់ឃើញ និងបានទាំងចូលរួមចំណែកក្នុងកិច្ចការសប្បុរសធម៌នោះផងដែរ។ លោកដារិតកំពុងតែឈររើសសំលៀកបំពាក់ បានអោយដឹងថាលោកក៏មានអារម្មណ៍រីករាយដែរចំពោះការចំណាយប្រាក់ទិញសំភារៈទាំងនេះ។

លោកបន្តថា៖ ព្រោះយើងដឹងថាអ្វីដែលយើងចំណាយគឺសំរាប់ជួយដល់អ្នកដទៃជាពិសេស គឺបានភ្លក់នូវមុខម្ហូបប្លែកៗរបស់ប្រទេសកូរ៉េផងដែរ៕ រឿន ស្រីម៉ាច

## Korean Christians hold a charity market

On February 23, a group of Christians from Korea arranged a market selling Korean products at St. Josepht parish (phsar Touch) the capital city of Phnom Penh. The profits from the sales goes to the poor in Cambodia.

Fr. In Don Francisco OH, the priest in charge of the Korean Missionary Society said that “these activities were initiated by Korean Catholic who live in Cambodia and who always attend Mass every week at the Church of Phsar Touch. The aim of this programme was to generate income for the Church to help the poor or use it for the needs of the Church.”

He contnued that all the expenses related to capital for this project was from the Korean Catholic themselves.

This was the first time that Korean Catholic initiated such a programme. The products that were put up for sale included: clothes, ice cream, noodles, kimchi (Korean vegetable delicacy), decorative materials from Korea, cooked food and other items, all of which were Korean.

Mrs. Sen Nary who bought some of the products said that she was happy with the programme because she saw products and other items of Korean origin for the first time ever and was also pleased that all this was for charity.

Mr. Darith who bought clothes and other items was pleased with what he bought. He continued by saying: “ this is a good experience of tasting Korean food and I am happy that the proceeds from the sales goes to the poor people.”

# លោកអភិបាលដាស់តឿនយុវជនឲ្យត្រៀមខ្លួនដើម្បីចូលសហគមន៍អាស៊ាន







រូបថត: លីហ៊ាង

ក្នុងជំនួបសំណេះសំណាល ជាមួយសិស្សស្នាក់នៅក្នុងមណ្ឌលសន្តយ៉ូហានបាទីស្ត និងមណ្ឌលសន្តយ៉ូសែប លោកអូលីវីយេ ជ្មីតអឺស្លែរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានក្រើនរំលឹកដល់សិស្សទាំងអស់ឲ្យខិតខំរៀនសូត្រ និងអានសៀវភៅឲ្យបានច្រើន ជាពិសេសត្រូវពង្រឹងខាងផ្នែកភាសាបរទេសនិងកុំព្យូទ័រ ព្រោះនាពេលអនាគតខាងមុខ កម្ពុជានឹងមានសមាហរណកម្មអាស៊ាន។

សមាគមអាស៊ានបានកំណត់យកថ្ងៃទី៣១ធ្នូ២០១៥ជាថ្ងៃបង្កើតសហគមន៍អាស៊ានមួយ ក្រោមពាក្យស្លោកថា "វាសនាតែមួយអត្តសញ្ញាណតែមួយ" ដោយប្រជាជនអាស៊ានអាចធ្វើដំណើរដោយគ្មានលិខិតឆ្លងដែន ទិដ្ឋាការ និងលំហូរទំនិញធ្វើឡើងដោយសេរី ដែលមានចំនួន១០ ប្រទេសចូលរួម។ ក្នុងនោះមានម៉ាឡេស៊ី ឥណ្ឌូនេស៊ី សិង្ហបុរី ហ្វីលីពីន ថៃ មីយ៉ាន់ម៉ា ឡាវ ប្រ៊ុយណេ វៀតណាម និងប្រទេសកម្ពុជា។

លោកអភិបាលបានបន្តថា៖ ហេតុនេះយើងត្រូវយកចិត្តទុកដាក់ការពារនិងថែរក្សាវប្បធម៌ និងមានចិត្តស្មោះដោយមានទំនួលខុសត្រូវ ដើម្បីប្រទេសកម្ពុជាទាំងមូល។ កម្មវិធីចុះទៅសួរសុខទុក្ខ និងសំណេះសំណាលនេះ បានធ្វើឡើងកាលពីល្ងាចថ្ងៃទី១៤កុម្ភៈនៅក្នុងព្រះវិហារសន្តយ៉ូសែបផ្សារតូចរាជធានីភ្នំពេញ។

មណ្ឌលសន្តយ៉ូសែប ទទួលសិស្សដែលកំពុងសិក្សានៅអនុវិទ្យាល័យ រីឯមណ្ឌលសន្តយ៉ូហានបាទីស្តទទួលសិស្សរៀននៅវិទ្យាល័យ ដែលសរុបមានសិស្ស ចំនួន៣០នាក់ ជាបុរស៕

ជាលីស

## Bishop exhorts youth to prepare for Asean integrate

In a frienldy meeting with students of the centers of St. John Baptist and of St. Joseph, bishop Olivier Schmitthaeusler, of the capitial city of Phnom Penh exhorted all the students to try hard to study and read more books. He called on them to especially strenghten themselves in foreign languages and computer knowledge because in the future, Asean (Association of South East Asia Nations) country including Cambodia, will integrate together. Asean countries chose December 31, 2015, to integrate together as a one community with a slogan "one destiny one identity". On that date, the Asean countries have the free flow, travelling will be visa free as well as free trade, like Indonesia, Malaysia, Thailand, Singapore, Vietnam, Brunei, Laos, Cambodia, Myanmar, and the Philippines. "That's why we have to carefully protect and maintain cultures and have the honest heart to be responsible for Cambodia as whole," said the bishop. The visitation and meeting programmes was initiated on the evening of February 14, 2014 by St. Joseph church (phsar toich), in Phnom Penh.

The center of St. Joseph received junior high school students, and the center of St. John Baptist received high school, both are a total of 30 male students.

# ក្រុមសន្តីតេរេសានៃព្រះកុមារយេស៊ូទួលក្រសាំង

យុវជនយុវនារីចំនួន១២រូប តែងតែជួបជុំគ្នា និងមានសកម្មភាពជាប់ជាមួយព្រះសហគមន៍ ជារៀងរាល់ថ្ងៃដែលមានឈ្មោះថា ក្រុមសន្តីតេរេសានៃព្រះកុមារយេស៊ូ ដោយជួបជុំគ្នាអធិដ្ឋាននិងចែករំលែកព្រះគម្ពីរជារៀងរាល់ល្ងាច នៅព្រះវិហារសន្តយ៉ូសែបទួលក្រសាំង ដែលមានទីតាំងនៅ ឃុំរការខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល និងមានសកម្មភាពផ្សេងៗ ជាមួយអ្នកភូមិជុំវិញផងដែរ។

យុវជន សុទ្ធ សន្ថា ជាប្រធានក្រុមបានឲ្យដឹងថា៖ ព្រះសហគមន៍បង្កើតក្រុមសន្តីតេរេសានេះឡើង គឺដើម្បីឲ្យគ្រីស្តបរិស័ទចេះយកគំរូតាមសន្តីតេរេសានៃព្រះកុមារយេស៊ូ ដោយចេះអធិដ្ឋានទៅកាន់ព្រះជាម្ចាស់ ហើយយកចិត្តទុកដាក់ទៅនឹងចាស់ជរា ស្រឡាញ់បរិស្ថាន និងចេះស្រឡាញ់គ្នាទៅវិញទៅមក។

បងប្រុសវឿង (Br. Vuong) ជាអ្នកទទួលខុសត្រូវលើក្រុមនេះមានប្រសាសន៍ថា៖ ក្រុមសន្តីតេរេសាបាន បង្កើតនាខែតុលា ឆ្នាំ២០១២ កន្លងទៅ។ បងប្រុសបានបន្ថែមថា ៖ សព្វថ្ងៃខ្ញុំកំពុងតែយកចិត្តទុកដាក់ចំពោះក្រុមនេះ ដើម្បីឲ្យពួកគាត់ចេះបង្ហាញធម៌មេត្តាករុណា ដល់បងប្អូនឯទៀតៗក្នុងសង្គម និងព្រះសហគមន៍ និងចង់ឲ្យក្រុមនេះរៀនឲ្យបានច្រើន ដោយចេះជំនាញផ្សេងៗ ព្រោះពួកគាត់គឺជាអនាគតរបស់ព្រះសហគមន៍ដែលត្រូវប្រកាសដំណឹងល្អ។

បងប្រុសវឿងបន្ថែមថា៖ ជារៀងរាល់ថ្ងៃយុវជន និងកុមារបានមកព្រះសហគមន៍រៀនភ្លេង និងអក្ខរកម្មភាសាវៀតណាមនិងខ្មែរ។ ហើយក្រុមនេះក្នុងមួយសប្តាហ៍ម្តងមានសកម្មភាព២គឺសម្អាតបរិស្ថានជុំវិញភូមិ និងចុះសួរសុខទុក្ខជនក្រីក្រដោយមានអំណោយមួយចំនួនជូនពួកគាត់ផងដែរ។

បងប្រុសបន្តថា៖ ក្នុងមួយសប្តាហ៍សមាជិកនៃក្រុមសន្តីតេរេសានៃព្រះកុមារយេស៊ូបានរៃអង្គាសគ្នា ជាកញ្ចប់ថវិកាមួយដើម្បីសកម្មភាពរួមរបស់ក្រុម។ ក្រុមសន្តីតេរេសានៃព្រះកុមារយេស៊ូ មានសមាជិកចំនួន១២នាក់ ដែលមានអាយុពី ១១-១៦ឆ្នាំ។

យុវតី ស៊ីណាជាសមាជិកនៃក្រុមនេះបានប្រាប់ថា៖ក្រុមនេះបានធ្វើឲ្យខ្ញុំមានចិត្តកែប្រែចិត្តគំនិតដោយងាកមកជួយជនក្រីក្រនិងក្មេងកំព្រា ចុះសួរទុក្ខអ្នកជិតខាង ព្រមទាំងចេះសន្សំថវិការួមគ្នា ដើម្បីទិញគ្រឿងឧបភោគបរិភោគខ្លះៗ ដល់ពួកគាត់(ក្រីក្រ)ជារៀងរាល់ខែ។ ស៊ីណា បានបញ្ជាក់ទៀតថា៖ ចាស់ៗទាំងនោះមិនដែលប្រកាន់សាសនានិងស្រឡាញ់ក្រុមសន្តីតេរេសានៃព្រះកុមារយេស៊ូដូចកូនបង្កើតរបស់ពួកគាត់ផងដែរ៕ ដាលីស



រូបថត: ដាលីស

## St. Therese of Child Jesus group at Toul Krasang

Twelve youth meet together to plan and carry out activities in the Church every evening. They call themselves "Group of St. Therese of Child Jesus". They meet to pray and share the Scriptures in the evenings at St. Joseph Church (Toul Krasang) located in Rokas Ppuas, Sa'ang district, Kandal province. They also carry out other good activities by joining the villagers.

The leader of this group, Soth Santha, said that the parish had started this group so that Christians will follow the example of St. Therese of the Child Jesus by praying to God and be mindful of the needs of the elderly people, to love the environment and also to love one other.

Bro. Vuong, the person responsible for the group said that the Group of St. Therese was formed on October 2012. He added that "today I am taking care of this group so that they show mercy to others in the society and the Church and I also want this group to learn more skills because they are the future of the Church who will proclaim the Good News."

Bro.Vuong added that every day youth and children arrive at the Church to learn music and Khmer-Vietnamese language. This group has two activities in a week: cleaning the village and visiting the poor with some gifts for them. He also said that for a week, the members of the group of St. Therese of the Child Jesus raise funds in order to meet the expenses for the groups' activities.

The Group of Therese of Child Jesus consists of 12 young people aged 11-16. A young girl Sina, a member of this group said that this group makes people have a change of heart to help the poor and orphaned children, visiting neighbours as well as saving money together to buy essential items for them to live, like food and household items every month. Sina emphasized that the elderly people do not discriminate on religious basis and love the group of St. Therese of the Child Jesus like their own siblings.

# សិក្ខាសាលាបំប៉នយុវជនបំរើអាសនៈ នៅព្រះសហគមន៍កាតូលិកបឹងទំពុន

សិក្ខាសាលាអំពីការបម្រើអាសនៈ បានរៀបចំឡើងនៅព្រះសហគមន៍បឹងទំពុន កាលពីថ្ងៃទី២២ កុម្ភៈ២០១៤ ដោយមានសិក្ខាកាមចូលរួមចំនួន ១២ នាក់។ សិក្ខាសាលានេះ ណែនាំដោយលោកបូជាចារ្យ វ៉ាំងសង់ និង លោក ដាមីញ៉ាំង។

លោក ហួត បូ៉រ៉ា ជាអ្នកសម្របសម្រួលក្រុមនេះ បានឲ្យដឹងថា ៖ ការរៀបចំសិក្ខាសាលានេះ ក្នុងគោលបំណង ពង្រឹងយុវជនស្ម័គ្រចិត្តទាំងនោះស្វែងយល់បន្ថែមអំពីការរៀបចំអាសនៈ និងដង្ហាយហើយយល់ពីអត្ថន័យនៃតម្លៃអាសនៈ អគ្គសញ្ញាព្រះកាយ និងព្រះលោហិតព្រះគ្រីស្តក្នុងអភិបូជា។ លោកបានបន្តទៀតថា ៖ យុវជនខ្លះ មានការនឿយណាយ ក្នុងការបម្រើអាសនៈ តែក្រោយពីបញ្ចប់សិក្ខាសាលានេះ ពួកគាត់មានការចាប់ចិត្តក្នុងការងារនេះថែមទៀត ដោយនៅលើអាសនៈគឺដូចជានៅក្បែរព្រះយេស៊ូដែរ។

យុវជន រត្ន័ ជាសិក្ខាកាម បានឲ្យដឹងថា ៖ សិក្ខាសាលានេះពិតជាល្អ និងជួយឲ្យលោកបានយល់ពីអត្ថន័យ និងតម្លៃនៃការបម្រើអាសនៈ។

លោកបូជាចារ្យ ហ្វានី ដាមីញ៉ាំង ជាអ្នកបង្រៀននៅក្នុងសិក្ខាសាលានេះមានប្រសាសន៍ថា ៖ អ្នកបំរើអាសនៈ ជាគ្រីស្តបរិស័ទ ឬជាអ្នកត្រៀមខ្លួនជាគ្រីស្តបរិស័ទ ត្រូវការស្វែងយល់ពីអាថ៌កំបាំងរបស់ព្រះជាម្ចាស់ខ្លះៗ អស់មួយជីវិត។ លោកបន្ថែមថា៖ លោកបូជាចារ្យដែលទទួលខុសត្រូវ ចាំបាច់ស្គាល់អ្នកបម្រើអាសនៈ ទើបអាចអប់រំតាមរបៀបមួយដែលស្របទៅនឹងសេចក្តីត្រូវការ និងជំនឿរបស់ពួកគាត់ ដើម្បីឲ្យធ្វើកាយវិកាត្រឹមត្រូវក្នុងព្រះវិហាររបស់ខ្លួនល្អជាង ។

សូមបញ្ជាក់ថា សិក្ខាសាលាអប់រំដល់អ្នកបម្រើអាសនៈ ត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំនៅព្រះសហគមន៍កាតូលិកបឹងទំពុន៕

សុជា ម៉េងហ៊ា

## Seminar to train altar servers at BoeungTumpong Church

A seminar for Altar Servers was conducted at Boeung Tumpong Church on February 22, 2014. Twelve persons participated in this programme conducted by Frs. Vincent and Damien Farhner.

Mr. Huot Bora, coordinator of the program said that the seminar is aimed at strengthening the youth in their understanding of their role as altar servers which also includes the preparation of the altar for the Liturgy and to understand the significance of the altar, the sacraments, in particular the Eucharist. He explained that some youth were tired of serving at the altar and he hoped this seminar will encourage them to take their roles seriously with dedication as it is like being near Jesus.

A participant, Roth, said that the seminar was very good and helped him understand the meaning and the value of being an altar server.

Fr. Damien, said that altar servers can be Christians or those preparing to become Christians and who have to understand about God's mystery for all. He added that a responsible priest is needed to know and understand altar servers so that he can educate them according to the needs and build their faith and teaching them to behave properly in church. Training of Altar servers is conducted every year at Boeung Tumpong Church.


រូបថត: ម៉េង ហ៊ី

# លោកបូជាចារ្យអានទៅបន្តការសិក្សា



រូបថត: សុជីវិទ្ធ

លោកមុលទ្រី ត្រៃរង្គ ហៅអាន ជាបូជាចារ្យជំនួយនៅមណ្ឌលសកម្មភាពខេត្តតាកែវ ត្រូវបានប្រធានក្រុមគ្រួសារសាសនទូតថៃបញ្ជូនទៅបន្តការសិក្សានៅបរទេសក្នុងពេលឆាប់ៗខាងមុខនេះ។

នៅក្នុងកម្មវិធីជំរាបលា និងអរគុណរូបលោក ដែលបានមកបម្រើការងារនៅក្នុងមណ្ឌលសកម្មភាពតាកែវ កាលពីថ្ងៃទី២៣ កុម្ភៈនេះ លោកអូលីវីយេ ឆ្មឺត អឺស្លែរជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ មានប្រសាសន៍ថា៖ លោកបូជាចារ្យអានគឺជាគ្រូគង្វាល ដ៏សប្បុរសម្នាក់ និងបានជួយឲ្យព្រះសហគមន៍មណ្ឌលសកម្មភាពតាកែវមានការរីកចម្រើនដូចសព្វថ្ងៃ។

លោកគ្រូ កុល ជៀង តំណាងអោយមណ្ឌលសកម្មភាពតាកែវទាំងមូលបានថ្លែងថា៖ គ្រីស្តបរិស័ទទូទាំងខេត្តតាកែវ មានការសោកស្តាយជាខ្លាំង ដោយត្រូវឃ្លាតឆ្ងាយពីលោកឪពុកដែលប្រៀបដូចជាញាតិសន្តានយ៉ាងជិតស្និទ្ធម្នាក់។ លោកគ្រូបានបន្តទៀតថា៖ ពួកគាត់នឹកចងចាំអនុស្សាវរីយ៍ ជាមួយរូបលោកជានិច្ចហើយក៏ទន្ទឹងរង់ចាំការវិលត្រឡប់របស់លោកផងដែរ។

យុវជនរ័ត្ន ចន្ថា ជាប្រធានកាយឫទ្ធិនៅព្រែកប្បាសបានសម្តែងនៅភាពសោកស្តាយ ថ្លែងទាំងអួលដើមកថា៖ ដំណឹងថាលោកឪពុកអានត្រូវឃ្លាតឆ្ងាយគឺជាការបាត់បង់មួយយ៉ាងធំរបស់យើងនិងព្រះសហគមន៍សន្តីតេរេសាព្រែកប្បាស។ ព្រោះលោកជាបូជាចារ្យមួយរូប ដែលបានខិតខំយកចិត្តទុកដាក់កសាងព្រះសហគមន៍ និងមានទំនាក់ទំនងល្អជាមួយបងប្អូនឯទៀត ទាំងក្នុងនិងក្រៅព្រះសហគមន៍ផងដែរ។

លោកបូជាចារ្យ មុលទ្រី ត្រៃរង្គ បានប្រាប់អោយដឹងថា៖រយៈពេល ពីរឆ្នាំពេញដែលបាននៅបម្រើក្នុងមណ្ឌលសកម្មភាពតាកែវធ្វើឲ្យខ្ញុំមានអំណរសប្បាយជាមួយគ្នាដូច ជាបងប្អូនបង្កើតហើយខ្ញុំសង្ឃឹមថាបងប្អូនគ្រីស្តបរិស័ទទាំង អស់ចូលជ្រៅនៅក្នុងជំនឿដែលខ្លួនមាន ដើម្បីជួយព្រះសហគមន៍របស់យើងទាំងអស់គ្នា។ ទន្ទឹមគ្នានោះផងដែរលោកបូជាចារ្យរូបនេះ បានចែកឈើឆ្កាងជូនបងប្អូនដែលបានចូលរួមក្នុងពិធីបុណ្យអភិបូជា ប្រមាណ១៥០នាក់ដើម្បីទុកជាអនុស្សាវរីយ៍៕

សុជីវិទ្ធ

## Fr. Ann to pursue further studies

Fr. Trirong Multri nicknamed Fr.Ann, the assistant parish priest of Takeo province's pastoral district will be sent by his Thai Missionary superior to pursue furher studies abroad as soon as possible. At the farewell function for Fr. Ann on the 28 February, the bishop of Phnom Penh, Rt. Rev. Olivier Schmitthaeusler thanked him for serving Takeo province and attending to its pastral needs.

The bishop also said that Fr. Ann is a good pastor and has helped the district grow well as can been seen today.

Mr. Kol Cheang , representative of Takeo province's whole pastoral district said that all the Christians in Takeo province felt very saddened by the depature of the Fr. Ann as he is like a close relative. He continued that they will keep fond memories of him forever and also look forward to his return.

Rath Chanta, leaderof Scout movement at Prekabas, expressed his emotional feelings by saying that "the news of Fr. Ann's departure will be a big loss of us and for the church of St. Therese at Prakabas. Fr. Ann is a priest who had tried hard to build the Church and had a good relationship with also the people of other religious beliefs."

Fr. Trirong Multri, in his farewell address said that "I have served two full years in Takeo province's pastoral district and has brough me a lot of joy as experienced by siblings and I hope that the community will continue to grow deeply in faith which will help build the church." As a parting gift Fr. Ann gave a crucifix to each of the 150 people who attended service as a souvenir.

# យុវជនយុវនារី ១៦០នាក់ ស្វែងយល់ពីឆ្នាំសម្ដែងធម៌មេត្តាករុណា

យុវជនយុវនារីប្រមាណជា១៦០នាក់ មកពីព្រះសហគមន៍កាតូលិកមណ្ឌលសកម្មភាពកំពត កែប និងកំពង់សោម បានជួបជុំគ្នាក្នុង អង្គសិក្ខាសាលាមួយដែលរៀបចំដោយការិយាល័យយុវជន និងកុមារនៅព្រះសហគមន៍កាតូលិកសន្តយ៉ូសែបជុំគិរី ស្ថិតក្នុងខេត្តកំពត។ អង្គសិក្ខាសាលាបានប្រព្រឹត្តទៅពីថ្ងៃទី១៥ដល់ទី១៦ខែ កុម្ភៈ២០១៤ រិះគិតលើប្រធានបទ " តើឆ្នាំសម្ដែងធម៌មេត្តាករុណាជាអ្វី? "។

កញ្ញា យុន កញ្ញា មន្ត្រីសម្របសម្រួលមួយរូបក្នុងអង្គសិក្ខាសាលានេះ បានឲ្យដឹងពីគោលបំណងដ៏សំខាន់របស់សិក្ខាសាលានេះថា៖ គឺឲ្យយុវជនយុវនារីមាន ឱកាសរិះគិតពីរបៀបសម្ដែងមេត្តាករុណា និងរិះគិតវាយតម្លៃពីសកម្មភាពកន្លងមកដើម្បីអរព្រះគុណព្រះជាម្ចាស់។

កញ្ញា សៀន ធីតា ជាយុវជនមកពីព្រះសហគមន៍កោះស្លាបាននិយាយថា៖ នាងពិតជាមានអំណរសប្បាយពេលបានជឿលើព្រះយេស៊ូ គឺនាំឲ្យនាងចេះចែករំលែកសេចក្ដីស្រឡាញ់ចំពោះអ្នកដទៃ ចេះជួយអ្នកក្រីក្រដែលជួបការ លំបាកហើយក៏នាំឲ្យនាងចេះកែប្រែចិត្តគំនិត និងមានភាពក្លាហានជាងមុន។ ធីតាបានបន្ថែមទៀតថា នេះជាអំណោយទានរបស់ព្រះជាម្ចាស់ដែលបានប្រទានឲ្យខ្ញុំ។

យុវជនត្រាវ នី មកពីព្រះសហគមន៍កំពង់ សោមបញ្ជាក់ថា៖ ខ្ញុំមានអារម្មណ៍ថាមានភាពស្និទ្ធស្នាលជាមួយគ្នាដូចបងប្អូន ហើយខ្ញុំទទួលបាននូវបទពិសោធន៍ថ្មីនិងយល់កាន់តែច្បាស់នូវប្រធានបទនេះ។ លើសពីនេះទៅទៀតគឺធ្វើឲ្យខ្ញុំដឹងថាទង្វើរបែបណាដើម្បីក្លាយជាយុវជនល្អ ហើយយកគំរូតាមព្រះយេស៊ូ៕ សុភី



រូបថត: កញ្ញា

## 106 youth attend seminar on " the Year of Charity"



រូបថត: កញ្ញា

An estimated 106 participants from the Catholic Church's pastoral district of Kompot and Kompong Som attended a seminar conducted by the Pastoral Office for Youth and Children at St. Joseph's (Chumkiri) in Kompot. The seminar, which was held on 15-16 February, 2014, focused on "understanding the Year of Charity".

Mrs. Khun Kanha, coordinator of the seminar explained that the main aim of the seminar was to give the youth an opportunity to reflect on how to show mercy and evaluate activities in order to thank God.

Mrs. Sien Thida, a participant from Koh Sla Church said that she was very happy to have faith in Jesus, which inspired her to share her love for others, help the poor who are experiencing difficulties and also to repent and be more brave. Thida added that "this is a joy that God has given to me."

Another participant, Trav Ny from Kompong Som Church said, "I felt togetherness among all the brothers and sisters and I gained a new experience and better understand of the topic. Furthermore, it makes me know how to behave and become a good youth and follow the example of Jesus."

# ដំណើរទស្សនកិច្ចរបស់លោកអភិបាលភ្ន

## Bishop’s visit to Phnm Penh

លោកអូលីវីយេផ្មឺតអឺស្លែជាអភិបាលនៃភូមិភាគភ្នំពេញបានចុះទស្សនកិច្ចផ្លូវការ នៅតាមបណ្តាព្រះសហគមន៍នានានៅមណ្ឌលសកម្មភាពភ្នំពេញខាងជើង ក្នុងគោលបំណងសួរសុខទុក្ខ និងលើកទឹកចិត្តដល់គ្រីស្តបរិស័ទព្រមទាំងស្វែងយល់ពីជីវិតរបស់ព្រះសហគមន៍ទាំងនោះផងដែរ។ ដំណើរទស្សនកិច្ចនេះ ប្រព្រឹត្តទៅរយៈពេលមួយសប្តាហ៍ពីថ្ងៃទី ១២-



១៧កុម្ភៈ២០១៤កន្លងទៅនិងអមដំណើរដោយលោកបូជាចារ្យនៃមណ្ឌល សកម្មភាព គឺ លោក រឿង ផ័ត្រសិរី និងលោកអាដ្រីយ៉ាន បេនីតេស ហ្វូស្តារ៉ូ។

លោកបូជាចារ្យ រឿង ផ័ត្រសិរី ជាបានមានប្រសាសន៍ថា៖ សកម្មភាពនេះពិតជាល្អ ព្រោះជាទំនាក់ទំនងដ៏ល្អរវាងលោកអភិបាល និងគ្រីស្តបរិស័ទដែលបង្ហាញថាលោកគឺជាគង្វាលពិតប្រាកដរបស់ភូមិភាគ និងជាឱកាសល្អរបស់លោកអភិបាលដើម្បីបានឃើញសភាពពិតនៃការរស់នៅ ទាំងផ្លូវកាយនិងផ្លូវវិញ្ញាណតាមព្រះសហគមន៍នីមួយៗ ដែលមានភាពខុសៗគ្នា ហើយយល់ពីសភាពការណ៍ក្នុងភូមិរបស់គ្រីស្តបរិស័ទ។

លោកបូជាចារ្យរូបនេះបានបញ្ជាក់ទៀតថា៖ លោកអភិបាលអូលីវីយេ បានផ្លាស់ប្តូរយោបល់ល្អៗជាច្រើន និងភាពចាំបាច់ក្នុងការអភិវឌ្ឍតាមព្រះសហគមន៍នីមួយៗ ដូចជាកម្មវិធីអប់រំ និងសកម្មភាពសម្តែងមេត្តាករុណាជាដើម។

រីឯលោកសុគាជាលេខាធិការក្រុមសង្គហៈនៃព្រះវិហារសន្តយ៉ូសែបផ្សារតូចបានឲ្យដឹងថា៖ លោកអភិបាលបានកោតសរសើរចំពោះក្រុមនានានៃមណ្ឌលសម្មភាព ព្រះសហគមន៍និងបានជំរុញ ឲ្យមានសកម្មភាពបន្ថែមទៀត ឆ្នាំសម្តែងធម៌មេត្តាករុណានេះ។

លោកសុគាបន្តថាក្រុមសង្គហៈក្នុងផ្សារតូច បានរក្សាសកម្មភាពជាមួយអ្នកក្រីក្រ និងមានសកម្មភាពថ្មីមួយទៀតគឺយកពេលវេលាទៅសួរសុខទុក្ខបងប្អូនគ្រីស្តបរិស័ទ ដែលបានឃ្លាតឆ្ងាយពីព្រះសហគមន៍ ដើម្បីភ្ជាប់ទំនាក់ទំនងគ្នាជាបងប្អូនក្នុងអង្គព្រះគ្រីស្ត។ ក្នុងដំណើរទស្សនកិច្ចនេះលោកអភិបាលអូលីវីយេ បានចុះទៅតាមព្រះសហគមន៍នានាមានដូចជា៖ ព្រះវិហារសន្តយ៉ូសែប (ផ្សារតូច) ព្រះវិហារព្រះមាតានៃសន្តិភាព(អរិយក្សត្រ) ព្រះវិហារសន្តសិលា(ពោធិ៍ធំ) ព្រះវិហារសន្តយ៉ូសែប(ក្តីកណ្តាល) ព្រះវិហារសន្តីម៉ារីម៉ាដាឡា(គីឡូលេខ១១) ព្រះវិហារសន្តយ៉ូសែប(សែនសុខ)
និងព្រះសហគមន៍ព្រែកតាទែន៕ ដាលីស









រូបថត: សុធីរិទ្ធ

រូបថតរបស់លោកអភិបាលនៅក្នុងដំណើរទស្សនកិច្ចនា
ថ្ងៃទី ១២ ដល់ថ្ងៃទី ១៧ កុម្ភៈ

# មណ្ឌលសកម្មភាពភ្នំពេញខាងជើង

## northern pastoral centre









*រូបថត: លីហៀង*

Photo Activities of Bishop Olivier to Northern Pastoral Centre
On 12th-17th February

Olivier schmitthaeuler, bishop of the Phnom Penh diocese officially arrived at Churches of Phnom Penh northern pastoral centre with a view to visting and encouraging Christians as well as learning to understand the life of those Churches. The visit took place a week



ago on February 12-17, 2014 and accopanied by Frs. Chatsirey Roeung, \Gustavo Adrian Benitez.

Fr. Chatsirey Roeung said that these activities are very good ones because it is a good relationship between the bishop and Christians showing that he [bishop] is a real pastor of the diocese and it is a good opportunity of the bishop to see the situation of living phisically and spiritually within each Church in a diffirent fashion and understand about the situation of Christians in villagesThe father said that bishop Olivier has traded good opinions and necessities of development within each Church such as education programs and a sign of showing mercy.

The secretary of Charity group of St.Joseph Parish (PhsarTouch) , Mr. Sokea said that the bishop has spoken in admiration about groups of the pastoral centre and encouraged more activities of the Year of Charity. He goes on to say the PhsarTouch's Chairity have carried out activities with the poor and another new activity is to take time to visit Christians far away from the Church to tie together in Christ.

During that time, the bishop has visited Churches: St. Joseph Parish (Phsar Touch), Queen of Peace Church (Areyksat), St. Peter Church (Po Thom), St. Joseph Church (Kdey Kandal), St. Mary Madalen's Church (Kiloleuk 11), St. Joseph's Church (Sen Sok) and Prek Ta Ten Church.

# ក្រុមអេម៉ាណូអែលរិះគិតពីជំនឿលើព្រះជាម្ចាស់

យុវជនក្រុមអេម៉ាណូលភូមិភាគភ្នំពេញបានមកជួបជុំគ្នារិះគិតអំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ ក្រោមប្រធានបទជំនឿ លើព្រះជាម្ចាស់នាថ្ងៃទី ២២ - ២៣ កុម្ភៈ ២០១៤នេះ នៅមណ្ឌលសកម្មភាពភ្នំពេញថ្មី នៅខណ្ឌសែនសុខ រាជធានីភ្នំពេញ។

លោកអ៊ុនសុន ជាបូជាចារ្យទទួលខុសត្រូវលើក្រុមអេម៉ាណូអែលមានប្រសាសន៍ថា៖ ព្រះសហគមន៍បានរៀបចំប្រធានបទនេះឡើងដើម្បី ជួយដល់ជំនឿរបស់យុវជនឲ្យចេះសម្តែងសកម្មភាពនៃជំនឿមកខាងក្រៅ គឺជួយរំលែកទុក្ខព្រួយជួយទុក្ខធុរៈអស់អ្នកដែលត្រូវការយើង ។ ម្យ៉ាងទៀតព្រះសហគមន៍ចង់ឲ្យយុវជនកាន់តែស្គាល់ព្រះជាម្ចាស់ និងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដែលជាប្រភពនៃជីវិតរបស់យើងផងដែរ។

លោកបន្តថា៖ គំនិតនិងប្រាជ្ញារបស់មនុស្សមានព្រំដែនតែចំពោះព្រះជាម្ចាស់គឺគ្មានព្រំដែនឡើយ។ តាមពិតជំនឿលើព្រះជាម្ចាស់មានន័យថា ខ្ញុំមានកម្លាំងនិងសមត្ថភាពមិនគ្រប់គ្រាន់ តែខ្ញុំផ្ញើជីវិតនិងពឹងផ្អែកលើព្រះជាម្ចាស់ដែលគ្មានព្រំដែន។

យុវជន ច្រិច ស៊ិន មកពីព្រះសហគមន៍ គងនយ បានប្រាប់ជីវិតថា៖ បន្ទាប់ពីបានចូលរួមសិក្ខាសាលានេះមក និងបានស្តាប់ពីបទពិសោធន៍ និងការបង្រៀនរបស់លោកឪពុកបប់ អំពីប្រធានបទ "ជំនឿលើព្រះជាម្ចាស់ " មក ធ្វើឲ្យខ្ញុំមានជំនឿកាន់តែរឹងមាំ និងយល់ពីអត្ថន័យនៃបូជាចារ្យ។ ក្រុមអេម៉ាណូអែលជាក្រុមយុវជនដែលកំពុងរិះគិតអំពី ការត្រាស់ហៅរបស់ព្រះជាម្ចាស់ជាអ្នកបួស។ ក្រុមនេះ បានបង្កើតក្នុងឆ្នាំ ១៩៩៩ ហើយបច្ចុប្បន្នមានយុវជនចំនួន២រូបបានក្លាយជាឧបដ្ឋាក ដែលនឹងត្រៀមខ្លួនក្លាយជាបូជាចារ្យកាតូលិក នាពេលខាងមុខនេះ។ តាមរយៈកម្មភាពក្រុមនេះក៏មានយុវជន



រូបថត: សុធីរិទ្ធ



រូបថត: សុធីរិទ្ធ

ប្រមាណ៤នាក់ផ្សេងទៀត ដែលកំពុងរៀននៅក្នុងទេវវិទ្យាល័យកម្ពុជាផងដែរ៕

ដាលីស

## Emmanuel group reflects on "faith in God"

On February 22-23, 2014, the Emmanuel youth of the Phnom Penh diocese met to reflect on the call of God, on the theme, "faith in God", at Phnom Penh Thmey pastoral center in Khan Sensok, in the capital city of Phnom Penh. Fr. Un Son, the priest in charge of the Emmanuel group said that the Church has set this theme to inspire the youth to better understand faith, to help share the pains and sorrows with those who need us. The Church also wants the youth to know God better and to understand His mercy, which is the source of our lives. He continued by saying that the minds and intelligence of human beings is limited unlike for God which is unlimited. In fact, the faith in God means that one has enough strength and capacity to put one's life aside and depend on the infinite God. A participant, Chrech Sin, from Kong Noy Church said, " having participated in the seminar and hearing of the experiences and sharings of Fr. Bob about 'faith in God', has strengthened my faith and understanding about the meaning of the priesthood." Emmanuel is a vocation promotion group reflecting on the call of God to the priesthood [religious life]. The group was formed in 1999 and now two youth have become deacons to be ordained Catholic priests soon. Thanks to the groups' commitment, there are now another four youth studying at the Major Seminary.

# សិក្ខាសាលាគ្រូមត្តេយ្យភូមិភាគភ្នំពេញ



រូបថត: ពឿន

អង្គសិក្ខាសាលាស្តីអំពីបច្ចេកទេសនិទានរឿងនិងបូកសរុបលទ្ធផលការងារសំរាប់ឆ្នាំ២០១៣ ដែលបានប្រព្រឹត្តទៅនៅរសៀលថ្ងៃទី២៦ ដល់២៨ខែកុម្ភៈឆ្នាំ២០១៤ នៅព្រះសហគមន៍កាតូលិកសន្តមីកាអែលក្រុងព្រះសីហនុ ដោយមានសិក្ខាកាម ចំនួន ៥៧ នាក់ជាគ្រូសាលាមត្តេយ្យនៃព្រះសហគមន៍នានា ក្នុងភូមិភាគភ្នំពេញក្រោមអធិបតីភាពរបស់អតីតអភិបាលអ៊ីវ៉ារ៉ាមូសនិងលោកបូជាចារ្យអ៊ុនសុន។

អ្នកស្រី ង៉ុយ គីមច័ន្ទដាវី ជាអ្នកសម្របសម្រួលកម្មវិធីសាលាមត្តេយ្យភូមិភាគភាពទាំងមូល បានពន្យល់ពីគោលបំណងនៃអង្គសិក្ខាសាលាយ៉ាងនេះថា គឺជួយគ្រូទាំងអស់ឲ្យមានការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ចេះបច្ចេកទេសនិទានរឿងឲ្យកុមារស្តាប់ ចេះមានគំនិតច្នៃប្រឌិតល្បែងផ្គុំរូប ផលិតសំភារៈផ្សេងៗដើម្បីអោយកុមារលេង។ ជាងនេះគឺពង្រឹងនូវសមត្ថភាព និងចំណេះដឹងបន្ថែមដល់អ្នកគ្រូទាំងអស់។

លោកបូជាចារ្យអ៊ុនសុនមានប្រសាសន៍ថា៖ លោករីករាយដោយបានឃើញស្នាមញញឹមរបស់គ្រូម្នាក់ៗ ហើយលោកក៏បានជំរុញដល់ គ្រូទាំងអស់ឲ្យយកចិត្តទុកដាក់និងធ្វើជាអំបិលនិងពន្លឺដើម្បីណែនាំដល់កុមារទាំងអស់។

នៅក្នុងពេលនោះដែរ លោកអភិបាលអ៊ីវ៉ារ៉ាមូសបានថ្លែងផ្តាំផ្ញើដល់គ្រូទាំងអស់ ឲ្យគោរពតួនាទីរបស់ខ្លួនដោយធ្វើជាគ្រូ និងជាម្តាយដ៏ជាទីស្រលាញ់ និងផ្តល់ភាពកក់ក្តៅដល់កុមារ និងបង្រៀនពួកគេឲ្យ មានចំណេះដឹងពិតប្រាកដដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍ និងសង្គមជាតិរបស់យើង៕

ពឿន

## Seminar on Story-telling for pre-school teachers

A seminar on "story-telling techniques" was held on February 26-28, 2014 at St. Michael's Parish (Sihanouk Ville) attended by 57 trainees, pre-school teachers from the Phnom Penh diocese. The seminar was facilitated by former Bishop Yves Ramousse and Fr. Son Un. The session also included some aspects of reviewing their work for the year 2013 and identifying areas of weakness and strengths in their work.

Ms. Ngoy Kim Chandavy, coordinator of the pre-school curriculum explained that the aim of the seminar was to help the participants to exchange experiences, story-telling techniques, organize games, identify materials for children to play. Furthermore, this experience strengthens the capacity and knowledge of the teachers.

Fr. Son Un said that he was happy to see the smile on the faces of the participants and he also encouraged all the teachers to be careful and serve as the salt and light to guide all the children.

Bishop Yves Ramousse's message to all the teachers was to respect their roles in serving as a loving teacher and mother and give warmth to children by teaching them to have knowledge for the sake of the church and our society.



រូបថត: ពឿន

# គ្រីស្តបរិស័ទវៀតណាមបង្ហាញមេត្តាករុណាដល់អ្នកក្រីក្រនៅព្រែកដាច់

ដោយទទួលបានការឧបត្ថម្ភ ពីក្រុមទេសចរណ៍ជាគ្រីស្តបរិស័ទមកពីប្រទេសវៀតណាម នៅព្រះវិហារសន្តអង់ទន់ (កំពង់ចម្លង) ស្ថិតនៅភូមិព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្តាល បានរៀបចំពិធីចែកអំណោយដល់ប្រជាជនក្រីក្រ ចំនួន២០០គ្រួសារ និងកុមារចំនួន១០០នាក់ កាលពីថ្ងៃទី ១២ ខែកុម្ភៈ កន្លងទៅនេះ។

តាមប្រសាសន៍បងប្រុស ថាញ់ជាអ្នកទទួលខុសត្រូវនៅព្រះសហគមន៍ ខាងលើបានឲ្យដឹងថា៖ ភ្ញៀវទាំងនោះបានមើលឃើញ ពីភាពលំបាករបស់ជនក្រីក្រនៅប្រទេសកម្ពុជាទាំងខ្មែរ និងវៀតណាម និងដោយមានការស្នើសុំពីបងប្រុសទៀតនោះ គ្រីស្តបរិស័ទទាំងនោះក៏បានចូលជាវិភាគទានដល់ព្រះសហគមន៍។ បងប្រុសបានបន្ថែមទៀតថា៖ អំណោយដែលត្រូវផ្តល់ឲ្យអ្នកក្រីក្រក្នុងមួយគ្រួសារ រួមមានអង្ករ១០ គីឡូក្រាម ស្ករស ទឹកត្រី ទឹកស៊ីអ៊ីវ និងប្រេងឆាជាដើម។

បងប្រុសថាញ់បានឲ្យដឹងទៀតថា៖ សព្វថ្ងៃបងប្រុសកំពុងតែទាក់ទង ជាមួយក្រុមទេសចរណ៍គ្រីស្តបរិស័ទវៀតណាមចំនួនពីរក្រុមផ្សេងទៀត ដែលនឹងមកប្រទេសកម្ពុជានាពេលខាងមុខ ដើម្បីជួយដល់ប្រជាជនក្រីក្រនៅក្នុងភូមិព្រែកដាច់។

ព្រះសហគមន៍កាតូលិកព្រែកដាច់ មានសកម្មភាពយ៉ាងសកម្ម ក្នុងការសម្តែងធម៌មេត្តាករុណាជាមួយអ្នកក្រីក្រនិងចាស់ជរាដោយមានជូនជាថវិកា សម្រាប់គ្រឿងឧបភោគបរិភោគទៅតាមលទ្ធភាពរបស់ព្រះសហគមន៍ និងមានកម្មវិធីបង្រៀនអក្ខរកម្ម ចំពោះកុមារ៣០នាក់ដែលមានអាយុ៦ឆ្នាំដល់៩ឆ្នាំផងដែរ ឲ្យចេះអាននិងសរសេរ។៚ ដាលីស



រូបថត: បងប្រុសថាញ់



រូបថត: បងប្រុសថាញ់

## Vietnamese Christians show concern to the poor at Prek Dech

With the help of Christian Tourists from Vietnam, Sant Antoine Church (KompongChamlang) located in Prek Dek village, Leuk Dek district, Kandal province, organized a programme distributing food parcels to 200 poor families and 100 children on February 2014.

According to Bro. Thanh responsible for this project said that those tourists saw the difficulites of the poor people consisting of both Cambodians and Vietnamese. He even received donations for the church. Bro. Thanh added that the parcels for each family included 10 kilogrammes of rice, white sugar, fish sauce, soy sauce, oil and other essentials.

He also said that recently he is keeping in touch with two other tour groups of Vietnamese Christians who will arrive in Cambodia soon to help the poor in Prek Dek village.

Prek Dech Church shows much concern for the poor and elderly by providing help in obtaining daily essentials like utencils and food according to its ability which also includes a literacy program for 30 children aged from six to nine by teaching them how to read and write.

# សៀវភៅអប់រំជំនឿថ្មីនឹងត្រូវបោះពុម្ពនៅឆ្នាំ២០១៥




មណ្ឌលអប់រំជំនឿព្រះសហគមន៍កាតូលិក ហៅកាត់ថា (ស៊ីស៊ីស៊ីស៊ី) នឹងរៀបចំបោះពុម្ពសៀវភៅអប់រំជំនឿចំនួន២ក្បាលបន្ថែមទៀត ទាក់ទងនឹងព្រះគម្ពីរសម្ពន្ធមេត្រីថ្មីនិងចាស់ដែលនឹងគ្រោងបោះពុម្ពផ្សាយនៅដើមឆ្នាំ២០១៥ខាងមុខនេះ។

លោក ដួង សាវង់ជាប្រធាន មណ្ឌលនេះបានមានប្រសាសន៍ឲ្យដឹងដូចនេះថា៖ សៀវភៅទាំងពីរនោះមាន ចូលនិទានពីព្រះយេស៊ូប្រាប់យើង ដែលជាអត្ថបទគម្ពីរដកស្រង់ចេញពីសៀវភៅសម្ពន្ធមេត្រីថ្មី និងសៀវភៅមួយទៀតគឺចូលនិទានពីសម្ពន្ធមេត្រីចាស់ប្រាប់យើង ជាអត្ថបទគម្ពីរដកស្រង់ចេញពីសៀវភៅសម្ពន្ធមេត្រីចាស់។

លោកបានឲ្យដឹងទៀតថា៖ កំរិតសៀវភៅទាំងពីរនេះគឺមានគោលបំណងបំពេញចន្លោះខ្វះខាត ក្នុងវិស័យអប់រំជំនឿក្នុងព្រះសហគមន៍កាតូលិក ដែលសព្វថ្ងៃព្រះសហគមន៍មានតែសៀវភៅ៧ក្បាលដើម្បីប្រើប្រាស់នៅទូទាំង បីភូមិភាគ។ លោកបានបន្តថា៖ ចំពោះខ្លឹមសារសៀវភៅថ្មីទាំងពីរនោះ គឺដូចទៅនឹងសៀវភៅដែលយើងធ្លាប់មាន តែខុសប្លែកត្រង់របៀបក្នុងការណែនាំ គឺសិល្បវិធីផ្នែកគរុកោសល្យតែប៉ុណ្ណោះ។

បច្ចុប្បន្នសៀវភៅអប់រំជំនឿរបស់ព្រះសហគមន៍កាតូលិក មានពីរប្រភេទ គឺមួយសំរាប់អប់រំមនុស្សពេញវ័យ និងមួយទៀតសំរាប់អប់រំកុមារតូចៗ ដែលមានឪពុកម្តាយជាគ្រីស្តបរិស័ទ។ សៀវភៅថ្មីដែលកំពុងតែរៀបចំនេះ គឺនឹងត្រូវបានប្រើប្រាស់សំរាប់ការអប់រំកូនក្មេងនិងវ័យជំទង់ ចាប់ពី៦ឆ្នាំដល់១៧ឆ្នាំ។ មណ្ឌលអប់រំជំនឿព្រះសហគមន៍កាតូលិក ជាមណ្ឌលកណ្តាលមួយ សម្រាប់ព្រះសហគមន៍កាតូលិក ទាំងបីភូមិភាគដែលធ្វើការក្នុងវិស័យអប់រំជំនឿ ក្នុងនោះមាន សកម្មភាព និងកម្មវិធី ដូចជា រៀបចំសិក្ខាសាលាអំពីការអប់រំជំនឿជាប្រចាំឆ្នាំដល់គ្រូអប់រំជំនឿ បង្កើតសៀវភៅអប់រំជំនឿ ដែលជាឯកសារជំនួយផ្សេងៗជួយដល់ផ្នែកអប់រំជំនឿ បង្កើតឧបករណ៍អប់រំជំនឿ និងចុះតាមដានតាមព្រះសហគមន៍ នានាអំពីការអប់រំជំនឿដោយស្តាប់យោបល់ និងចែករំលែក

## New Catechism books to be published in 2015

The Cambodian Catholic Catechetical Center (CCCC) is planning to publish two more catechism books focusing on the Old and New Testaments in the Bible in the year 2015.

Mr. Duong Savong, director of the center said that these two books titled "Let us tell about Jesus!" a bible passage quoted from the New Testament and the other "Let us tell about the Old Testament!".

He said that the level of understanding of the books are intended to narrow the gap in various Catechetical education sectors of the Catholic Church in Cambodia. The Church today has only seven books to be used across the three dioceses. He went on to say that basically the essence of the two books are like the previous publications but differs in pedagogical approach.

Currently, in the Catholic Church in Cambodia there are two versions of catechism books; one for adults and the other for children whose parents are Christians. Hence, these new books are being prepared taking this into consideration and will be used to educate children and adolescents aged six to eleven years of age.

The Cambodian Catholic Catechetical Center is a central body for the three dioceses in the country. Some of the common activities and programmes include annual catechetical seminars for catechists and visiting parishes to do research and receive comments and opinions and also sharing experiences with the catechists in the various parishes.

## ធម្មទេសនាក្នុងឱកាស
## ទស្សនកិច្ចរបស់លោកអភិបាល ក្នុងមណ្ឌលសកម្មភាពភ្នំពេញខាងជើង
## នៅព្រះវិហារសន្តៈ យ៉ូសែប ១៦/ ០២/ ២០១៤

**បងប្អូនជាទីស្រឡាញ់!**

ថ្ងៃនេះ ព្រះយេស៊ូមានព្រះបន្ទូលថា៖ សូមកុំនឹកស្មានថាខ្ញុំមកលុបបំបាត់ធម្មវិន័យ ឬពាក្យប្រៀនប្រដៅរបស់ព្យាការី ចោលឡើយ ខ្ញុំមកដើម្បីឲ្យគម្ពីរមានអត្ថន័យពេញលេញវិញ។ ពេលនោះមានគេឆ្ងល់ថាតើព្រះយេស៊ូមានព្រះបន្ទូលអំពីអ្វី។ នៅសម័យនោះជនជាតិយូដាកាន់សាសនាយូដា គេមានវិន័យ១០ប្រការរបស់លោកម៉ូសេ ហើយគេក៏មានវិន័យ៦០០ ថែមទៀតដែលអនុញ្ញាតឲ្យធ្វើនេះឬមិនឲ្យធ្វើនោះជាដើម។គេមានធម្មវិន័យច្រើនមែនទែននិងព្រះយេស៊ូមានព្រះបន្ទូលថា៖ ខ្ញុំមិនមកដើម្បីបំផ្លាញធម្មវិន័យ ប៉ុន្តែខ្ញុំមកដើម្បីបំពេញធម្មវិន័យឲ្យបានពេញលក្ខណៈវិញ។

អត្ថបទថ្ងៃនេះណែនាំឲ្យយើងចូលយ៉ាងជ្រៅអំពីអត្ថន័យនៃដំណឹងល្អសម្រាប់ជីវិតរបស់យើង។នៅក្នុងធម្មវិន័យរបស់លោកម៉ូសេបានចែងថា កុំសម្លាប់មនុស្ស។ ព្រះយេស៊ូយល់ព្រមទាំងស្រុង ប៉ុន្តែព្រះអង្គទៅជ្រៅជាងនេះទៀត ដោយព្រះអង្គបានបន្ថែមថា រីឯខ្ញុំវិញ ខ្ញុំសូមបញ្ជាក់ប្រាប់អ្នករាល់គ្នាថា អ្នកណាខឹងនឹងបងប្អូន អ្នកនោះនឹងត្រូវគេផ្តន្ទាទោសដែរ។ ដូច្នេះព្រះយេស៊ូមិនគិតត្រឹមតែការសម្លាប់មនុស្ស ប៉ុន្តែព្រះអង្គគិតទៅដល់មូលហេតុនៃការសម្លាប់។ កំហឹងណែនាំឲ្យយើងវាយគេឬអាចសម្លាប់គេបាន។ ដូច្នេះព្រះយេស៊ូបំពេញធម្មវិន័យ ដោយព្រះអង្គបានទៅដល់ប្រភពនៃអំពើបាបទាំងអស់។ នេះជារបៀបដែលព្រះយេស៊ូបំភ្លឺយើងគឺឲ្យយើងទៅដល់ប្រភពនៃអំពើបាបដែលយើងប្រព្រឹត្ត។ទីពីរគឺ"កុំប្រព្រឹត្តអំពើផិតក្បត់"ព្រះយេស៊ូបានបន្ថែមថា៖អ្នកណាមើលស្ត្រីម្នាក់ ហើយមានចិត្តស្រើបស្រាលចង់រួមបវេណីជាមួយនាង អ្នកនោះដូចបានប្រព្រឹត្តអំពើផិតក្បត់ដែរ។ ដូច្នេះ មើលប្រពន្ធគេ ឬស្រីនានាដោយមានចិត្តចង់រួមបវេណី នោះចាត់ទុកជាការប្រព្រឹត្តអំពើផិតក្បត់ដែរ។ ក្នុងធម្មវិន័យរបស់លោកម៉ូសេមានចែងថា៖ អ្នករាល់គ្នាកុំបំភ្លេចពាក្យសម្បថឡើយ ព្រះយេស៊ូមានព្រះបន្ទូលលើស ពីនោះទៀត គឺ៖ កុំស្បថឲ្យសោះ។ ព្រះយេស៊ូជួយយើងឲ្យទៅដល់ប្រភពនៃអំពើបាប ដើម្បីណែនាំឲ្យយើងចូលនៅក្នុងជីវិតថ្មីរួមជាមួយព្រះអង្គ។

ព្រះយេស៊ូយាងមកបំពេញធម្មវិន័យរបស់លោកម៉ូសេឯធម្មវិន័យរបស់ព្រះអង្គគឺ៖សូមស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។ អស់មួយជីវិតព្រះយេស៊ូបានណែនាំឲ្យយើងគិតអំពីរបៀបដូចមានចែងក្នុងអត្ថបទទីមួយថា៖ ព្រះអង្គដាក់ទឹកនិងភ្លើងនៅមុខកូន ពេលនោះកូនអាចលូកដៃជ្រើសរើសមួយណាក៏បានទឹកឬភ្លើង?។ ព្រះអង្គប្រទានមកមនុស្សនូវជីវិតនិងសេចក្តីស្លាប់ដែរ ដូច្នេះមនុស្សត្រូវជ្រើសរើស ទឹកឬភ្លើង ជីវិតឬសេចក្តីស្លាប់។ តាមធម្មវិន័យជនជាតិយូដាគ្មានសិទ្ធិធ្វើការអ្វីសោះនៅថ្ងៃសប្ប័ទ ប៉ុន្តែ ព្រះយេស៊ូប្រោសឲ្យអ្នកជំងឺជាសះស្បើយនៅថ្ងៃសប្ប័ទ។ មានគេរិះគន់ព្រះអង្គថាធ្វើខុសនឹងធម្មវិន័យរបស់លោកម៉ូសេព្រះយេស៊ូមានព្រះបន្ទូលថា៖យើងនាំឲ្យអ្នកជំងឺមានជីវិតឬយើងប្រហារជីវិតរបស់គាត់? ពេលនោះគេមិនអាចឆ្លើយបានទេ។ដោយសារព្រះយេស៊ូគិតដល់ប្រភពនៃជីវិត ដល់ប្រភពនៃសេចក្តីស្រឡាញ់ ដល់ប្រភពនៃធម្មវិន័យ ដូច្នេះធម្មវិន័យលែងសម្រាប់ឲ្យមនុស្សបម្រើទៀតហើយ ផ្ទុយទៅវិញធម្មវិន័យសម្រាប់បម្រើមនុស្សវិញ។ ដូច្នេះយើងជាគ្រិស្តបរិស័ទ ត្រូវពិចារណាគ្រប់កិច្ចការ តើយើងត្រូវដើរតាមផ្លូវដែលព្រះជាម្ចាស់បំភ្លឺ ឬដើរតាមផ្លូវនៃ សេចក្តីងងឹត។ ពេលយើងស្តាប់ធម្មវិន័យរបស់ព្រះយេស៊ូ ដូចជាស្រួលមែនទែន សូមស្រឡាញ់គ្នាទៅវិញទៅមក ប៉ុន្តែពេលយើងប្រព្រឹត្តមិនស្រួលប៉ុន្មានទេ។ប៉ុន្តែក៏ត្រូវតែដឹងដែរថា យើងអាចប្រព្រឹត្តបាននូវវិន័យទាំងឡាយ តែដោយសារព្រះជាម្ចាស់ ប្រទានសមត្ថភាពឲ្យយើង។

ថ្ងៃនេះយើងមានក្រុមសាម៉ូអែលចូលរួមជាមួយ ពេលយើងគិតដល់ព្រះជាម្ចាស់ត្រាស់ហៅ នោះយើងដឹងថាយើងគ្មានសមត្ថភាពនឹងឆ្លើយតបចំពោះព្រះអង្គដូចនាងម៉ារីដូចគ្រិស្តទូត និងដូចព្យាការីទាំងឡាយទេ ប៉ុន្តែព្រះជាម្ចាស់ប្រទានសមត្ថភាពឲ្យយើងអាចឆ្លើយបាននិងធ្វើបាន។ នៅពេលនាងម៉ារីឆ្លើយថា៖ នាងខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់នោះនាងដឹងថាព្រះជាម្ចាស់ប្រទានសមត្ថភាពដល់នាង។ ពេលយើងជាគ្រិស្តបរិស័ទប្រកាសថា៖ ពិតមែនខ្ញុំចង់ស្រឡាញ់អ្នកឯទៀតដូចព្រះយេស៊ូស្រឡាញ់ខ្ញុំនោះត្រូវដឹងថា យើងមានសមត្ថភាពអាចធ្វើបាន ដោយសារព្រះជាម្ចាស់ប្រទានសមត្ថភាពឲ្យយើង។ ឆ្នាំនេះជាឆ្នាំនៃធម៌មេត្តាករុណា ជាពេលវេលាមួយដើម្បីឲ្យព្រះសហគមន៍របស់យើងភ្ញាក់ស្មារតីជាថ្មី គិតថាតើយើងត្រូវធ្វើដូចម្តេច ដើម្បីបំពេញធម្មវិន័យរបស់ព្រះយេស៊ូ ដែលឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះអង្គបានស្រឡាញ់យើង។

នឹកឃើញដល់ប៉ុន្មានអាទិត្យមុន ក្នុងពិធីបើកឆ្នាំនៃធម៌មេត្តាករុណា យើងបានដាក់សំណួរថា អ្នកណាជាបងប្អូនរបស់ខ្ញុំ?

ដូច្នេះបីឆ្នាំខាងមុខនេះ យើងត្រូវការឆ្លើយ តើអ្នកណាជាបងប្អូនរបស់ខ្ញុំ? តើខ្ញុំត្រូវស្រឡាញ់អ្នកណា? ខ្ញុំត្រូវលើកទឹកចិត្តអ្នកណា? នេះជាអ្វីដែលយើងត្រូវពិចារណា។ រយៈពេលមួយអាទិត្យដែលខ្ញុំបានដើរតាមព្រះសហគមន៍នានា នៅក្នុងមណ្ឌលសកម្មភាពភ្នំពេញខាងជើងជាមួយលោក ផ័ត្រសេរី យើងបានទៅដល់ព្រះសហគមន៍គីឡូលេខ៩ ព្រែកតាទែនអន្លង់ក្ងាន ស្វាយប៉ាក។ ជាមួយលោកហ្គូស្តាវ៉ូ យើងបានទៅដល់ព្រះសហគមន៍ពោធិ៍ធំ ក្តីកណ្តាល អរិយក្សត្រ និងម្សិលមិញនៅផ្សារតូច។ នេះជាឱកាសមួយដើម្បីអរព្រះគុណព្រះជាម្ចាស់។ ក្នុងដំណើរនេះ ខ្ញុំបានសង្កេតឃើញថា ព្រះសហគមន៍នៅក្នុងមណ្ឌលសកម្មភាពភ្នំពេញខាងជើងនេះ បានយកចិត្តទុកដាក់បង្ហាញធម៌មេត្តាករុណា ផ្តល់សេចក្តីស្រឡាញ់ដល់បងប្អូនឯទៀតៗជាពិសេសដល់មនុស្សតូចតាច។ នៅគ្រប់កន្លែង យើងមានគណៈកម្មការសង្គហៈ និងមានគ្រីស្តបរិស័ទដែលយកចិត្តទុកដាក់ដល់បងប្អូនដែលកំពុងរស់នៅយ៉ាងលំបាកក្នុងពេលសព្វថ្ងៃ។ ខ្ញុំសូមរំឭកដល់គ្រីស្តបរិស័ទនៅមណ្ឌលភ្នំពេញខាងជើងថា ពេលណាយើងនិយាយអំពីអ្នកក្រីក្រ ពេលណាយើងនិយាយអំពីការលើកទឹកចិត្ត អំពីធម៌មេត្តាករុណា នោះយើងត្រូវនឹកឃើញអំពីតួនាទីរបស់យើងគឺ៖ ទីមួយ តើយើងត្រូវធ្វើដូចម្តេចដើម្បីបំពេញធម៌វិន័យរបស់ព្រះយេស៊ូ ដែលឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមក ស្រឡាញ់មនុស្សដែលអស់សង្ឃឹមដោយសារដាច់អាហារ ដោយសារបាត់បង់ដីធ្លី ដោយសារគ្មានសមត្ថភាពឲ្យកូនទៅរៀន ឬដោយសារគ្មានលុយព្យាបាលជំងឺ?។ នេះមិនមែនតែជាតួនាទីរបស់គណៈកម្មការនីមួយៗ តែជាតួនាទីរបស់យើងទាំងអស់គ្នានៅក្នុងមណ្ឌលសកម្មភាពភ្នំពេញខាងជើង។ យើងត្រូវសូមកម្លាំងពីព្រះជាម្ចាស់ ដើម្បីឲ្យយើងចូលយ៉ាងជ្រៅនៅក្នុងជីវិតរបស់បងប្អូន ដែលកំពុងអស់សង្ឃឹម ដែលខ្វះអ្វីៗទាំងអស់ ដើម្បីឲ្យពួកគាត់រស់នៅយ៉ាងសមរម្យក្នុងសង្គមនាពេលបច្ចុប្បន្ន។ យប់មិញ ក្នុងពេលអធិដ្ឋានជាមួយក្រុមយុវជន យើងបានភ្ជាប់ចិត្តទៅអ្នកពិការ អ្នកចាស់ជរា កុមារកំព្រា... ប៉ុន្តែយើងមិនត្រូវភ្ជាប់តែបបូរមាត់ ឬដោយគោលបំណងល្អនៅក្នុងចិត្តប៉ុណ្ណោះទេ គឺត្រូវចេញស្នាដៃជាក់ស្តែងតាមសមត្ថភាពរបស់យើង ដោយបង្ហាញសេចក្តីស្រឡាញ់យ៉ាងពិតប្រាកដ នេះហើយជាតួនាទីរបស់យើងជាព្រះសហគមន៍។

ចំណុចទីពីរ យើងត្រូវនឹកឃើញដល់បងប្អូនក្រីក្រទាំងអស់។ ប៉ុន្តែ បងប្អូនខ្លះមិនមែនក្រីក្រដោយសារខ្វះម្ហូបអាហារ ឬប្រាក់កាស តែក្រីក្រដោយសារឥតមានសេចក្តីសង្ឃឹម ឥតមានពន្លឺមួយដែលណែនាំឲ្យជីវិតរបស់គាត់មានអត្ថន័យ។ សុភមង្គលដ៏ពិតប្រាកដនៃជីវិត មិនមែនតាមរយៈសម្ភារៈ ប្រាក់កាសនោះទេ។ តាមព្រះយេស៊ូ សុភមង្គលដ៏ពិតប្រាកដគឺស្រឡាញ់គ្នាទៅវិញទៅមក។ ក្នុងទីក្រុង និងក្នុងមណ្ឌលសកម្មភាពរបស់យើង មានទាំងអ្នកក្រីក្រដោយខ្វះប្រាក់កាស សម្ភារៈ និងមានអ្នកក្រីក្រមួយប្រភេទទៀត ដែលមានផ្ទះស្អាត លុយច្រើន មានឡាន តែគេក្រីក្រខាងសេចក្តីសង្ឃឹម គេខ្វះពន្លឺគេមិនស្គាល់ព្រះយេស៊ូឡើយ។ ព្រះសហគមន៍នៅទីក្រុង ត្រូវតែភ្ញាក់ស្មារតីចំពោះសភាពការណ៍នេះ តើយើងត្រូវបើកទ្វារឲ្យគេចូលបានយ៉ាងដូចម្តេច? តើយើងឲ្យគេស្គាល់ព្រះយេស៊ូ ឲ្យគេឮអំពីសុភមង្គលដ៏ពិតប្រាកដ ឲ្យគេដឹងថាគេខ្វះពន្លឺមួយ ណែនាំឲ្យជីវិតរបស់គេមានអត្ថន័យដ៏ពិតប្រាកដយ៉ាងដូចម្តេច?...ព្រោះមនុស្សទាំងអស់មានសិទ្ធិស្គាល់មានសិទ្ធិស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូនេះជាតួនាទីរបស់យើងមួយទៀត។ ហេតុនេះហើយដើម្បីអាចទៅមុខបាន ដោយយើងជឿលើព្រះយេស៊ូដែលសោយទិវង្គតនិងមានព្រះជន្មរស់ឡើងវិញ នោះខ្ញុំសូមអញ្ជើញឲ្យបងប្អូនយើង អង្គុយសម្លឹងមើលព្រះយេស៊ូនៅលើឈើឆ្កាងដើម្បីប្រកាសយ៉ាងពិតប្រាកដថា៖ ខ្ញុំជឿលើព្រះយេស៊ូគ្រីស្ត ដែលសោយទិវង្គត់និងមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបីពិតប្រាកដមែន។

ថ្ងៃនេះមានបេក្ខជនបួននាក់ដែលប្រកាសជំនឿលើព្រះយេស៊ូ។ ប៉ុន្តែជំនឿ មិនមែនណែនាំយើង ឲ្យតែអង្គុយសម្លឹងមើលព្រះយេស៊ូ ដើម្បីទទួលសេចក្តីស្រឡាញ់ ទទួលជីវិតពីព្រះអង្គប៉ុណ្ណឹង ប៉ុន្តែជំនឿណែនាំយើង ឲ្យចូលនៅក្នុងព្រះយេស៊ូដើម្បីមើលឃើញពិភពលោក មើលឃើញបងប្អូនឯទៀតៗ ដោយភ្នែករបស់ព្រះយេស៊ូផ្ទាល់វិញ។ នៅលើឈើឆ្កាង ព្រះយេស៊ូសម្លឹងមើលមនុស្សលោកដោយអហិង្សាព្រះអង្គមិនខឹងមិនស្អប់មិនបន្ទោសនរណាទេព្រះអង្គសម្លឹងមើលមនុស្សលោកដោយចិត្តស្រឡាញ់និងដោយលើកលែងទោសឲ្យថែមទៀត។ប្រសិនបើយើងចូលនៅក្នុងព្រះយេស៊ូយ៉ាងជ្រៅបន្តិចម្តងៗជីវិតរបស់យើងនឹងទៅជាជីវិតថ្មី ដោយសារយើងមានភ្នែក មានបេះដូងដូចព្រះយេស៊ូ។ ពេលនេះខ្ញុំសូមសំណូមពរដល់ព្រះសហគមន៍ក្នុងមណ្ឌលសកម្មភាពភ្នំពេញខាងជើង សូមឲ្យយើងដូចព្រះយេស៊ូ ឲ្យយើងលះបង់ចោលប្រយោជន៍ផ្ទាល់ខ្លួនឲ្យយើងចូលនៅក្នុងព្រះយេស៊ូដើម្បីឲ្យព្រះសហគមន៍នីមួយៗ និងគ្រីស្តបរិស័ទម្នាក់ៗ ជាពិសេសនៅក្នុងទីក្រុងភ្នំពេញទៅជាវត្តមានរបស់ព្រះយេស៊ូនៅជាមួយបងប្អូនឯទៀតៗជាប្រចាំ។

ខ្ញុំសូមទូលអង្វរព្រះជាម្ចាស់ឲ្យយើងខិតខំបំពេញធម្មវិន័យរបស់ព្រះអង្គ ដោយយើងចេះស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះយេស៊ូបានស្រឡាញ់យើងដែរ៕

អាម៉ែន!

# សិស្សសន្តយ៉ូស្ទីនស្វែងយល់ពីនយោបាយ និងអាស៊ាន



រូបថត: ម៉ាលី

សាលាអប់រំជំនឿគ្រីស្តបរិស័ទសន្តយ៉ូស្ទីនបានរៀបចំសិក្ខាសាលាអំពីសង្គមក្រោមប្រធានបទ "ស្ថានភាពនយោបាយនៅប្រទេសកម្ពុជានិងសមាហរណកម្មអាស៊ាន" ដោយមានលោកបណ្ឌិត សុខ ទូចជាវាគ្មិន កាលពីថ្ងៃទី១៥ កុម្ភៈ នៅព្រះសហគមន៍សន្តយ៉ូសែបផ្សារតូចរាជធានីភ្នំពេញ។

លោកផុន សុផល ជានាយកសាលាសន្តយ៉ូស្ទីនមានប្រសាន៍ថា៖ ក្នុងមួយឆ្នាំសាលាមានកម្មវិធីសិក្ខាសាលាផ្សេងៗពីគ្នាដែលទាក់ទងនឹងនយោបាយ បញ្ហាសង្គម វប្បធម៌និងសាសនានានា។លោកបានបញ្ជាក់ថា៖កម្មវិធីនេះគឺដើម្បីឲ្យសិស្សមានគំនិតទូលាយ មិនមែនរៀនត្រឹមតែទេវវិទ្យានិងសាសនាប៉ុណ្ណោះទេ តែយល់ពីបរិបទនៃសង្គមទូទៅដែលតែងតែផ្លាស់ប្តូរ។ម៉្យាងវិញទៀត២០១៥ខាងមុខសមាហរណកម្មអាស៊ាននឹងបើកចំហរហេតុនេះទើបសាលាចង់ឲ្យនិស្សិតទទួលព័ត៌មានខ្លះដើម្បីត្រៀមខ្លួន។

ក្នុងកម្មវិធីនោះ លោកសុខ ទូចបានមានប្រសាសន៍ថា៖ ស្ថានភាពនយោបាយនៅកម្ពុជាកំពុងនៅជាប់គាំងនៅឡើយវាអាចនឹងប៉ះពាល់ ដល់ការធ្វើសមាហរណកម្មអាស៊ាននាពេលខាងមុខនេះ។ម៉្យាងវិញទៀតកម្ពុជានៅខ្វះខាតបុគ្គលិកជំនាញខាងបច្ចេកទេស ហើយកម្ពុជាក៏ត្រូវពង្រឹងលើវិស័យអប់រំតាំងពីថ្នាក់បឋមរហូតដល់កំរិតខ្ពស់បំផុតផងដែរ។ ក្នុងនោះដែរលោកក៏បានសង្កត់ធ្ងន់ថា៖ ត្រូវពង្រឹងទៅលើប្រព័ន្ធអប់រំឲ្យមានប្រសិទ្ធិភាព ដោយឲ្យមានមន្ទីរពិសោធន៍ត្រឹមត្រូវ ហើយទ្រឹស្តីត្រូវផ្សារភ្ជាប់ជាមួយពិសោធន៍។

លោកឌុយ សុផល ជានិស្សិតនៃសាលាសន្តយ៉ូស្ទីនបានមានយោបល់ថា៖ មតិរបស់លោកសុខ ទូច ពិតជាមានប្រយោជន៍ជាច្រើនសម្រាប់រូបលោក ដែលនឹងត្រូវត្រៀមខ្លួនប្រកួតប្រជែងនឹងទីផ្សារការងារថ្មីក្នុងពេលខាងមុខនេះ៕ ដាលីស

## Students of St. Justin learn to understand politics and Asean

St. Justin's School of faith conducted a social seminar to understand Cambodia's political situation and its integration into Asean's (Association of South East Nations) initiative next year.

The ASEAN Heads of State at their Summit in 2000 launched the Initiative for ASEAN Integration (IAI) with the objectives of Narrowing the Development Gap (NDG) and accelerating economic integration of the newer members of ASEAN, namely Cambodia, Lao PDR, Myanmar, and Viet Nam (CLMV).

The main speaker was Dr. Sok Touch and the seminar was held at the parish of St. Joseph (Phsar Touch), in the capital city of Phnom Penh on the 15th of February. In a year, the school holds separate seminars on politics, social issues, culture and religion. Mr. Phon Sophal , the director of St. Justin's school stressed that "these programmes are organised for the students to open their minds not only to the study of theology and religion but also understand the overall context of a society that is always changing. As part of preparations for the 2015 event, where the intergration of the Indochina countries into the mainstream development with the other members states, it is hoped such programmes will prepare the students to face the challenges ahead. Hence, such seminars are a good way to prepare the students for this approaching initiative as it wants the students to be well oriented in the overall concept."

Dr. Sok Touch also said that Cambodia's political situation is not necessarily conducive and it may affect the integration plan to come. Furthermore, Cambodia still lacks technically skilled staff and so it has to strengthen education sectors from primary to high school levels.

Mr. Duy Sophal, a student of St. Justin's school commented that Mr. Sok Touch's opinions are really useful for him so that he will face the opportunities for a new job market with the competition that will follow.

# ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ
## Apostolic Vicariate of Phnom Penh

### សកម្មភាពរបស់លោកអភិបាល អូលីវីយេ ស្មីតអឺស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ សម្រាប់ខែមីនា ឆ្នាំ ២០១៤

២ មីនា ៖អភិបូជានៅភ្នំពេញថ្មី និង២.៣០រសៀល
ប្រជុំជាមួយក្រុមសាសនទូតគ្រីស្តបរិស័ទ
៣ មីនា ៖៨.៣០ព្រឹក ប្រជុំអំពីការរៀចំកម្មវិធីសិក្សាមុខវិជ្ជា
សង្គមវិទ្យានៃវិទ្យាស្ថានសន្តប៉ូល
២រសៀល ប្រជុំជាមួយសម្ព័ន្ធកាតូលិកដើម្បីការ
អភិវឌ្ឍន៍ និងមេត្តាករុណា
៤ មីនា ៖សំណាក់ធម៌ជាមួយបូជាចារ្យនៅព្រះវិហារសន្ត
យ៉ូសែបផ្សារតូច និងទស្សនកិច្ចទេវវិទ្យាល័យ
៦ មីនា ៖ប្រជុំទីប្រឹក្សាបេសសកម្ម អធិដ្ឋានពេញមួយយប់
សម្រាប់ការត្រាស់ហៅនៅកំពត-
ព្រះសហគមន៍ព្រៃកប្រស់
៨-៩ មីនា ៖សំណាក់ធម៌សម្រាប់អ្នកត្រៀមធ្វើជំហានទី២ និងពិធី
បុណ្យអភិបូជាធ្វើជំហានទី២នៅព្រះវិហារសន្តយ៉ូសែប
ផ្សារតូច
១១ មីនា ៖ប្រជុំក្រុម **MEP**
១២ មីនា ៖ពិធីបុណ្យរំលឹកខួបមរណភាពរបស់លោកបូជាចារ្យ
ហ្វ្រង់ស្វ័រ គ្រៀង ប៊ូយៀប នៅព្រះវិហារផ្លូវត្រី
១៣ មីនា ៖ប្រជុំទីប្រឹក្សាបេសសកម្ម
១៤ មីនា ៖សួរសុខទុក្ខក្រុមសាសនទូតក្រៅប្រទេសកេបិក
១៥-១៦មីនា៖អភិបូជា និងសំណាក់ធម៌សម្រាប់រដូវអប់រំពិសេស
នៅក្រុងព្រះសីហនុ
១៧-១៩មីនា៖សន្និសីទនៅវិទ្យាស្ថានសន្តប៉ូល អំពី
ការចងចាំនិងអត្តសញ្ញាណ
២០ មីនា ៖បួនឆ្នាំនៃការតែងតាំងក្រុមទីប្រឹក្សា
២១ មីនា ៖ប្រជុំអ្នកសម្របសម្រួលមណ្ឌលសកម្មភាពភ្នំពេញថ្មី
២២ មីនា ៖បង្រៀនទេវវិទ្យានៅសាលាសន្តយ៉ូស្ទីន
២៣ មីនា ៖អភិបូជា និងសំណាក់ធម៌សម្រាប់រដូវអប់រំពិសេស
នៅមណ្ឌលសកម្មភាពបាសាក់
២៤ មីនា ៖ប្រជុំនៅភូមិសុខសាន្ត
២៥ មីនា ៖ទស្សនកិច្ចទេវវិទ្យាល័យ
២៦ មីនា ៖ប្រជុំជាមួយលោកអភិបាល និងតំណាងពេញសិទ្ធិ
លោកអភិបាល
ប្រជុំគណកម្មការមណ្ឌលនិស្សិត និងសួរសុខទុក្ខនិស្សិត
២៧ មីនា ៖ប្រជុំទីប្រឹក្សាបេសសកម្ម
២៨ មីនា ៖អភិបូជានៅអារាមកាម៉ែល និងសួរសុខទុក្ខសាលា
យ៉ូស្ទីនជាមួយអ្នកស្រី ក្លែ លី
២៩ មីនា ៖បង្រៀនអំពីលទ្ធិព្រះសហគមន៍កាតូលិកនៅ
សាលាយ៉ូស្ទីន
៣០ មីនា ៖អភិបូជា និងសំណាក់ធម៌សម្រាប់រដូវអប់រំពិសេស
នៅមណ្ឌលសកម្មភាពបឹងទំពុន
៣១ មីនា ៖ប្រជុំនៅវិទ្យាល័យសន្តហ្វ្រង់ស្វ័រ

### The Activities of Bishop Olivier SCHMITTHAEUSLER, MEP Apostolic Vicar of Phnom Penh in March 2014

2 March : Holy Mass at Phnom Penh Thmey
2.30pm Meeting with Lay Missionaries
3 March : 8.30 am : Meeting for Social Works curriculum Development
2 pm: Catholic Alliance for Development and Charity
4 March : Recollection with all priests at St Joseph
Visit at Major Seminary
6 March : Mission Council
Night Prayers for Vocation - Kampot / Prey Pros
8-9 March : Recollection for 2nd step and celebration of 2nd step (St Joseph)
11 March : MEP meeting
12 March : Celebration at Plov Trey - Father Hiep
13 March : Council Mission
14 March : Visit to Missionaries Quebec Foreign Society
15-16 March : Holy Mass and Recollection for Lenten Time at Sihanouk Ville
17-19 March : Symposium at St Paul: Memory and Identity
20 March : 4 years of Episcopal Ordination
21 March : Coordination Meeting for PP Thmey Pastoral Sector
22 March : Teach Theology at St Justin School
23 March : Holy Mass and Recollection for Lenten Time at Bassac
24 March : Peace Village
25 March : Major Seminary
26 March : Meeting with Bishops and General Vicars
Meeting of Committee ad hoc for Students Center / Visit of Students Center
27 March : Mission Council
28 March : Carmel St Justin School with Claire Ly
29 March : Teach Social Doctrine of the Catholic Church at St Justin School
30 March : Holy Mass and Recollection for Lenten Time

at Boeung Toumpun
31March : Meeting at St Francis High School

# រូបភាពប្រចាំខែ Life

ឆ្នាំនៃធម៌មេត្តាករុណា
2014-2016

YEAR OF CHARITY


















## ភូមិភាគភ្នំពេញ

**APOSTOLIC VICARIATE PHNOM PENH**
អ្នកទទួលខុសត្រូវ: លោកអភិបាល អូលីវីយេ ស្មីតហឺស្លែរ
Chairman: Msgr. Olivier Schmitthaeusler
Tel: 023 64 00 841
Email: apostolicvicariate.phnompenh@gmail.com
#25, St242, Boeung Prolit, 7Makara, Phnom Penh.

## អេម៉ាណូអែល

សម្លេងព្រះសហគមន៍កាតូលិករៀងរាល់ថ្ងៃ
តាមរយៈវិទ្យុសម្លេង FM104 Mhz
វេលាម៉ោង ៥:០០-៦:០០ ល្ងាច

## កម្មវិធីវិទ្យុ “ខ្ញុំត្រូវការអ្នក”

តាមរយៈវិទ្យុសម្លេង FM99.5Mhz
រៀងរាល់ថ្ងៃ អង្គារ
វេលាម៉ោង ១០:០០-១១:០០ ព្រឹក